ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ១៨៧៩ ព.ណ.អ.ស.ស

ថ្ងៃដុត ១២រោច ខែ ភាទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០២៤

ជម្រាបមក

លោក/លោកស្រីប្រធានក្រុមហ៊ុន រ៉ូយ៉ាល់ ជ្រេហ្គន អេនើជី អ៊ឹមផត អិចផត ៦.ក

កម្មវត្ថុ: ការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលប្រេងរំអិលសម្រាប់យានយន្តគ្រប់ប្រភេទ ប្រេងរំអិល ប្រេងព្រាំង ប្រេងបូម ប្រេងចង្កូត ប្រេងកាឡេ ប្រេងម៉ាស៊ូត ប្រេងឥន្ធនៈ ប្រេងរំអិលប្រើក្នុងឧស្សាហកម្ម (ក្រៅពីប្រេងដែលអាចបរិភោគបាន និងប្រេងផ្សេងៗទៀត)ម៉ាក TWISTER Super Lubricants របស់ក្រុមហ៊ុន **រ៉ូយ៉ាល់ ជ្រេហ្គន អេនើជី អ៊ឹមផត អិចផត ៦.ក** ក្នុងព្រះរាជាណាចក្រកម្ពុជា។

យោង: - មាត្រា ៣ និងមាត្រា ១១នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតរបស់ក្រុមហ៊ុន **រ៉ូយ៉ាល់ ជ្រេហ្គន អេនើជី អ៊ឹមផត អិចផត ៦.ក** ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០២៤
- លិខិតប្រគល់សិទ្ធិផ្តាច់មុខបន្តរបស់ក្រុមហ៊ុន SUN SIAM CO., LTD. ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០២៤
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៦២៧៤៦/១៧ ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០១៧។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលប្រេងរំអិលសម្រាប់យានយន្តគ្រប់ប្រភេទ ប្រេងរំអិល ប្រេងព្រាំង ប្រេងបូម ប្រេងចង្កូត ប្រេងកាឡេ ប្រេងម៉ាស៊ូត ប្រេងឥន្ធនៈ ប្រេងរំអិលប្រើក្នុងឧស្សាហកម្ម (ក្រៅពីប្រេងដែលអាចបរិភោគបាន និងប្រេងផ្សេងៗទៀត)ពាក់ម៉ាកខាងលើ របស់ក្រុមហ៊ុន **រ៉ូយ៉ាល់ ជ្រេហ្គន អេនើជី អ៊ឹមផត អិចផត ៦.ក** ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលទទួលបានពីក្រុមហ៊ុន SUN SIAM CO., LTD. ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខដែលក្រសួងបានតម្កល់ទុករួចហើយ។

លិខិតកត់ត្រា និងតម្កល់សិទ្ធិផ្តាច់មុខនេះមានសុពលភាពត្រឹមថ្ងៃទី ១២ ខែសីហា ឆ្នាំ២០២៥ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិមុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន SUN SIAM CO., LTD. ដែលជាម្ចាស់ម៉ាក។

ចាប់ពីក្រោយរយៈពេល ៩០(កៅសិប)ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខនេះអ្នកទទួលសិទ្ធិស្របច្បាប់មានសិទ្ធិប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការរារាំងទំនិញដែលនាំចូលស្របគ្នា។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខត្រូវផ្សព្វផ្សាយលិខិតខាងលើនេះជាបន្ទាន់ក្នុងទំព័រខាងមុខរបស់សារព័ត៌មានក្នុងព្រះរាជាណាចក្រកម្ពុជា និងបណ្តាញសង្គមនានា ហើយត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

ជម្រាបមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

អ៊ុក-ប្រុជ

ចម្លងជូន:
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ឧទ្ទេសនាម សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី*
- *ឧទ្ទេសនាម ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា*
- *ឧទ្ទេសនាម ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*
- *ឧទ្ទេសនាម ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (ក.ប.ប)*
- *អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*
- *អគ្គនាយកដ្ឋានពន្ធដារ*
- *ឯកសារ-កាលប្បវត្តិ*

ទូរស័ព្ទលេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61,Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469